ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.........

# ប្រកាស
# ស្ដីពី
# នីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់

# ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្ដីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្ដីពីកិច្ចសម្រួលពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដំឡើងសាខាគយនិងរដ្ឋាករចំនួន ២ ទៅជានាយកដ្ឋានស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៦៣ សហវ.ប្រក.អគរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋាន ក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីវិធាននិងនីតិវិធី សម្រាប់ការរាយការណ៍អំពីទំនិញ (Cargo Declaration) និងការបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) តាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការនាំចូល និងការឆ្លងកាត់ តាមគ្រប់ប្រភេទមធ្យោបាយដឹកជញ្ជូន។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷

- មធ្យោបាយដឹកជញ្ជូន សំដៅដល់ជលយាន អាកាសយាន ឬមធ្យោបាយផ្សេងទៀតដែលប្រើប្រាស់សម្រាប់ដឹកជញ្ជូនមនុស្ស ឬទំនិញ។
- ឯកសារដឹកជញ្ជូន សំដៅដល់ឯកសារក្នុងទម្រង់ក្រដាសឬទម្រង់អេឡិចត្រូនិក ដែលរៀបរាប់លម្អិតអំពីការដឹកជញ្ជូនដែលបានកើតឡើង ឬនឹងកើតឡើង។ ឯកសារដឹកជញ្ជូន រួមមាន និវេទនបណ្ណទំនិញ អញ្ញាតបណ្ណ និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល ដែលអាចផ្ទៀងផ្ទាត់បានដោយគយ។
- និវេទនបណ្ណទំនិញ (Cargo Manifest) សំដៅដល់បញ្ជីរាយមុខទំនិញដែលដឹកជញ្ជូន តាមជលយាន អាកាសយាន ឬអយស្ម័យយាន នៃជើងដឹកជញ្ជូនជាក់លាក់។
- អញ្ញាតបណ្ណ (Waybill) សំដៅដល់ អញ្ញាតបណ្ណមេ និង/ឬអញ្ញាតបណ្ណរង។
- អញ្ញាតបណ្ណមេ (Master Bill of Lading/ Master Air Waybill) សំដៅដល់ឯកសារដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន មានបញ្ជាក់ពីព័ត៌មាននៃការដឹកជញ្ជូនទំនិញជាក់លាក់ឬកញ្ចប់ទំនិញរួមដែលចេញដោយប្រតិបត្តិករដឹកជញ្ជូនទំនិញឱ្យទៅប្រតិបត្តិករបញ្ជូនទំនិញ ឬប្រតិបត្តិករនាវាភារ-

វេទកិច្ច ក្រោយពីព្រមព្រៀងទទួលដឹកជញ្ជូនទំនិញទៅកាន់ទីកន្លែងជាក់លាក់ណាមួយ ស្របតាមលក្ខខណ្ឌនៃការដឹកជញ្ជូន។

- អញ្ញាតបណ្ណវង (House Bill of Lading/ House Air Waybill) សំដៅដល់ឯកសារដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន មានបញ្ជាក់ពីព័ត៌មាននៃការដឹកជញ្ជូនទំនិញជាក់លាក់ ដែលចេញដោយប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករបញ្ញើរហ័ស ឬប្រតិបត្តិករនាវាភាវវេទកិច្ច ក្រោយពីព្រមព្រៀងដឹកជញ្ជូនទំនិញពីអ្នកផ្ញើទំនិញ (Consignor) ទៅឱ្យអ្នកទទួលទំនិញ (Consignee) នៅទីកន្លែងកំណត់ណាមួយ។ អញ្ញាតបណ្ណវងអាចត្រូវបានចេញដោយប្រតិបត្តិករដឹកជញ្ជូនទំនិញ ក្នុងករណីម្ចាស់ទំនិញទទួលសេវាកម្មដឹកជញ្ជូនទំនិញដោយផ្ទាល់ពីប្រតិបត្តិករដឹកជញ្ជូនទំនិញ។
- ព័ត៌មានស្ថានភាពកុងតឺន័រ (Container Status Message - CSM) សំដៅដល់ព័ត៌មានអំពីស្ថានភាពផ្លាស់ទីរបស់កុងតឺន័រ ទោះបីជាកុងតឺន័រមានផ្ទុកទំនិញ ឬសំបកកុងតឺន័រទទេ។
- ប្រតិបត្តិករដឹកជញ្ជូនទំនិញ (Carrier) សំដៅដល់បុគ្គលដែលធ្វើប្រតិបត្តិការនិងមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើមធ្យោបាយដឹកជញ្ជូន រាប់បញ្ចូលទាំង បុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងនិងធ្វើប្រតិបត្តិការតាមរយៈកិច្ចសន្យាជួល និងប្រតិបត្តិករបញ្ញើរហ័ស ផងដែរ។
- ប្រតិបត្តិករនាវាភាវវេទកិច្ច (Non-Vessel-Operating Common Carrier - NVOCC) សំដៅដល់បុគ្គលដែលទទួលសិទ្ធិគ្រប់គ្រង និងធ្វើប្រតិបត្តិការនាវាតាមរយៈកិច្ចសន្យាជួល។
- ប្រតិបត្តិករបញ្ជូនទំនិញ (Freight Forwarder) សំដៅដល់បុគ្គលដែលផ្តល់សេវាកម្មបញ្ជូនទំនិញជំនួសឱ្យអតិថិជនរបស់ខ្លួន ដូចជាប្រមូលផ្តុំទំនិញ រក្សាទុកទំនិញ បង្រួមកញ្ចប់ទំនិញ ចាត់ចែងទំនិញឱ្យដឹកជញ្ជូនតាមមធ្យោបាយដឹកជញ្ជូនណាមួយ និង/ឬ រៀបចំឯកសារសម្រាប់នាំចេញ ឬនាំចូល។
- ប្រតិបត្តិករបញ្ញើរហ័ស (Express Courier) សំដៅដល់បុគ្គលដែលផ្តល់សេវាកម្មការដឹកជញ្ជូនទំនិញ ឬបញ្ជូនទំនិញ ជាប្រភេទបញ្ញើរហ័ស។
- ភ្នាក់ងារតំណាង (Agent) សំដៅដល់បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបានទទួលសិទ្ធិធ្វើជាអ្នកតំណាងឱ្យបុគ្គលដែលមានកាតព្វកិច្ចរាយការណ៍អំពីទំនិញ។
- កាលបរិច្ឆេទមកដល់នៃទំនិញ (Actual Date of Arrival) សំដៅដល់កាលបរិច្ឆេទ ដូចមានចែងក្នុងបញ្ញត្តិប្រការ៩ នៃប្រកាសនេះ។
- ប្រតិវេទន៍គយមុនពេលទំនិញមកដល់ (Pre-Arrival SAD) សំដៅដល់ប្រតិវេទន៍គយដែលបានប្រកាសមុនពេលទំនិញមកដល់ និងអាចត្រួតពិនិត្យដោយគយ។

**ប្រការ៤.-**

ទំនិញនាំចូល និងទំនិញឆ្លងកាត់ជាកម្មវត្ថុត្រូវរាយការណ៍ជូនរដ្ឋបាលគយមុនពេលទំនិញមកដល់ ក្នុងទម្រង់អេឡិចត្រូនិក។

**ប្រការ៥.-**

ឯកសារដឹកជញ្ជូនដែលជាកម្មវត្ថុត្រូវរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយរួមមាន និវេទនបណ្ណទំនិញ អញ្ញាតបណ្ណមេ អញ្ញាតបណ្ណរង និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល មានរៀបរាប់អំពីទំនិញ និងមធ្យោបាយដឹកជញ្ជូន ដែលនឹងត្រូវចូលមកដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

បុគ្គលដែលមានកាតព្វកិច្ចរាយការណ៍អំពីទំនិញ អាចបញ្ជូនទិន្នន័យទាំងនេះដោយត្រង់ពីប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួន មកកាន់ប្រព័ន្ធរបស់រដ្ឋបាលគយ (System to System) ឬបញ្ចូលទិន្នន័យដោយផ្ទាល់មកក្នុងប្រព័ន្ធដែលកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងករណីពុំមានប្រព័ន្ធអេឡិចត្រូនិក។

វិធីសាស្ត្រនិងបច្ចេកទេសប្រព័ន្ធ សម្រាប់ការរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ៦.-**

បុគ្គលដែលមានកាតព្វកិច្ចត្រូវរាយការណ៍អំពីទំនិញ ជូនរដ្ឋបាលគយ រួមមាន៖

- ប្រតិបត្តិករដឹកជញ្ជូនទំនិញ មានកាតព្វកិច្ចរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក នូវទិន្នន័យនិវេទនបណ្ណទំនិញ អញ្ញាតបណ្ណ និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល រួមទាំងព័ត៌មានស្ថានភាពកុងតឺន័រ។
- ប្រតិបត្តិករបញ្ជូនទំនិញ និងប្រតិបត្តិករនាវាភារវេទកិច្ច មានកាតព្វកិច្ចរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក នូវទិន្នន័យអញ្ញាតបណ្ណមេ(បើមាន) អញ្ញាតបណ្ណរង និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល។
- ប្រតិបត្តិករបញ្ញើរហ័ស មានកាតព្វកិច្ចរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក នូវទិន្នន័យនិវេទនបណ្ណទំនិញ(បើមាន) អញ្ញាតបណ្ណ និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល។
- ប្រតិបត្តិករផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

បុគ្គលរាយការណ៍អំពីទំនិញ អាចប្រើប្រាស់ភ្នាក់ងារតំណាង ដើម្បីរាយការណ៍ជំនួស ប៉ុន្តែត្រូវទទួលខុសត្រូវពីភាពត្រឹមត្រូវនៃការរាយការណ៍នោះ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចកំណត់លក្ខខណ្ឌ និងលក្ខណសម្បត្តិបុគ្គលដែលអាចមានសិទ្ធិធ្វើជាភ្នាក់ងារតំណាង។

**ប្រការ៧.-**

បុគ្គលមានកាតព្វកិច្ចរាយការណ៍អំពីទំនិញ ដូចមានចែងក្នុងបញ្ញត្តិប្រការ៦ នៃប្រកាសនេះ ត្រូវផ្តល់នូវឯកសារដឹកជញ្ជូនក្នុងទម្រង់អេឡិចត្រូនិក សម្រាប់គោលបំណងនៃការវិភាគវាយតម្លៃហានិភ័យ តាមពេលវេលាកំណត់ ដូចខាងក្រោម៖

**ក. ការដឹកជញ្ជូនតាមផ្លូវទឹក**

- ចំពោះទំនិញដែលផ្ទុកក្នុងកុងតឺន័រ ត្រូវរាយការណ៍មិនយឺតជាង ២៤(ម្ភៃបួន)ម៉ោង មុនពេលផ្ទុកក្នុងនាវា នៅកំពង់ផែចេញដំណើរចុងក្រោយ។

- ចំពោះទំនិញចាក់ធារ ទំនិញរាយមិនផ្ទុកក្នុងកុងតឺន័រ និងទំនិញជាវត្ថុធាតុរាវ ត្រូវរាយការណ៍មិនយឺតជាង ២៤(ម្ភៃបួន)ម៉ោង មុនពេលទំនិញមកដល់កំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា។

**ខ. ការដឹកជញ្ជូនតាមផ្លូវអាកាស**

ត្រូវរាយការណ៍មុនពេលអាកាសយានចាកចេញពីអាកាសយានដ្ឋានចេញដំណើរនៅបរទេស។

**គ. ការដឹកជញ្ជូនតាមផ្លូវគោក**

- ចំពោះទំនិញដឹកតាមរថយន្ត ត្រូវរាយការណ៍មិនយឺតជាង ១(មួយ)ម៉ោង មុនពេលមកដល់មាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ចំពោះទំនិញដឹកតាមរថភ្លើង ត្រូវរាយការណ៍មិនយឺតជាង ២(ពីរ)ម៉ោង មុនពេលមកដល់មាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៨.-**

បុគ្គលរាយការណ៍អំពីទំនិញអាចធ្វើការកែតម្រូវ បំពេញបន្ថែម ឬលុបព័ត៌មាននិង/ឬទិន្នន័យបាននៅមុនពេលទំនិញមកដល់ដែនគយនៃព្រះរាជាណាចក្រកម្ពុជា។ ព័ត៌មាននិងទិន្នន័យចុងក្រោយនៃការរាយការណ៍អំពីទំនិញ ត្រូវចាត់ទុកជាផ្លូវការនៅពេលទំនិញមកដល់។ ការកែតម្រូវ ការបំពេញបន្ថែម ការលុបព័ត៌មាននិង/ឬទិន្នន័យ នៅមុនពេលទំនិញមកដល់ ពុំជាកម្មវត្ថុនៃការរងពិន័យឡើយ។

បុគ្គលដែលបានរាយការណ៍អំពីទំនិញត្រូវជូនដំណឹងមករដ្ឋបាលគយ អំពីការមកដល់ឬខកខានមិនមកដល់ដែនគយនៃព្រះរាជាណាចក្រកម្ពុជា នៃទំនិញនិងមធ្យោបាយដឹកជញ្ជូន។

**ប្រការ៩.-**

កាលបរិច្ឆេទមកដល់នៃទំនិញ ត្រូវកំណត់ដូចខាងក្រោម÷

- ចំពោះការដឹកជញ្ជូនតាមផ្លូវទឹក ត្រូវកំណត់យកតាមកាលបរិច្ឆេទនៃទម្រង់ការបែបបទនាវា។
- ចំពោះការដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវកំណត់យកតាមកាលបរិច្ឆេទ ដែលទំនិញដាក់ចូលក្នុងសន្និធិគយបណ្ដោះអាសន្ន។
- ចំពោះការដឹកជញ្ជូនតាមផ្លូវគោក ត្រូវកំណត់យកតាមកាលបរិច្ឆេទដែលទំនិញមកដល់មាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១០.-**

ក្រោយពីការរាយការណ៍អំពីទំនិញមានលក្ខណៈគ្រប់គ្រាន់ ប្រតិវេទករអាចដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ ដោយត្រូវអមភ្ជាប់ជាមួយនូវឯកសារគាំទ្រនានាតាមមធ្យោបាយអេឡិចត្រូនិក ស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រោយពេលទំនិញមកដល់ "ប្រតិវេទន៍គយមុនពេលទំនិញមកដល់" នឹងត្រូវចុះបញ្ជីដោយស្វ័យប្រវត្តិទៅជា "ប្រតិវេទន៍គយ" ដែលជាកម្មវត្ថុនៃការអនុវត្តបន្តតាមបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយជាធរមាន។

**ប្រការ១១.-**

នីតិវិធីលម្អិតនៃការរាយការណ៍អំពីទំនិញ និងការដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ១២.-**

ប្រតិបត្តិករដឹកជញ្ជូនទំនិញ ប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករនាវាភារវេទកិច្ច ប្រតិបត្តិករបញ្ញើរហ័ស និងបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលមានកាតព្វកិច្ចរាយការណ៍អំពីទំនិញ ដែលខកខានក្នុងការអនុវត្តបញ្ញត្តិប្រការ៦ ប្រការ៧ និង/ឬបំពានបញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវរងការពិន័យរដ្ឋបាល និង/ឬទោសទណ្ឌផ្សេងទៀត តាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រតិបត្តិករពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី - ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ